**ពាក្យបណ្តឹងទៅកាន់ អង្គការសម្រាប់កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងការអភិវឌ្ឍន៍ (OECD) ៖ សហជីពវិស័យកាត់ដេរចំនួន ១៨, សម្ព័ន្ធប្រាក់ឈ្នួលអាស៊ី (AFWA) និងយុត្តិធម៌ការងារសកល - វេទិកាសិទ្ធិអន្តរជាតិ (GLJ-ILRF) *ទល់នឹង* ក្រុមហ៊ុនណៃគី (Nike, Inc.)**

<u>**សលាកបត្រព័ត៌មាន**</u>

**កុម្ភៈ ២០២៣**

---

*សហជីពវិស័យកាត់ដេរចំនួន ១៨, AFWA និង GLJ-ILRF ទល់នឹង Nike, Inc. គឺជាឧទាហរណ៍ជាក់លាក់មួយនៅក្រោមគោលការណ៍ណែនាំរបស់ OECD ស្តីពីការអនុវត្តសាជីវកម្មប្រកបដោយការទំនួលខុសត្រូវ។ ដោយសហជីពទាំង ១៨, AFWA និង GLJ-ILRF បានដាក់ពាក្យបណ្តឹងរួមគ្នា ទៅកាន់ការិយាល័យទំនាក់ទំនងកិច្ចការជាតិរបស់សហរដ្ឋអាមេរិក (NCP) សម្រាប់គោលការណ៍ណែនាំរបស់ OECD នៅក្នុងទីស្តីការរដ្ឋនៃសហរដ្ឋអាមេរិក។*

**កាលបរិច្ឆេទដាក់ពាក្យបណ្តឹង** ៖ ថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២៣

**សហជីព៖** សហជីពវិស័យកាត់ដេរចំនួន ១៨ មកពីប្រទេសកម្ពុជា ឥណ្ឌា ឥណ្ឌូនេស៊ី ប៉ាគីស្ថាន និងស្រីលង្កា ដែលក្រុមហ៊ុន Nike, Inc. មានរោងចក្រចំនួន ៩៣ នៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់របស់ខ្លួន និងមានកម្មករជាង ២០០,០០០ នាក់។

**សម្ព័ន្ធមិត្ត ៖** យុត្តិធម៌ការងារសកល - វេទិកាសិទ្ធិអន្តរជាតិ (GLJ-ILRF) និង សម្ព័ន្ធប្រាក់ឈ្នួលអាស៊ី (AFWA)

**អង្គហេតុ ៖** ចាប់តាំងពីការចាប់ផ្តើមរាតត្បាតនៃជំងឺកូវីដ១៩ នៅក្នុងខែមីនា ឆ្នាំ២០២០ កម្មករកាត់ដេរនៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់របស់ក្រុមហ៊ុន Nike បានជួបប្រទះនឹងការបញ្ចប់ និងការបញ្ឈប់ការងារដោយខុសច្បាប់ ការកាត់ប្រាក់ឈ្នួលតាមអំពើចិត្ត ការមិនបើកប្រាក់ឈ្នួលសម្រាប់ម៉ោងការងារដែលបានបំពេញ និងការរើសអើងយេនឌ័រក្នុងកម្រិតដែលមិនធ្លាប់មានពីមុនមក។ ក្រុមហ៊ុនម៉ូដធំៗ រួមទាំងក្រុមហ៊ុន Nike, Inc. ដែលជាក្រុមហ៊ុនម៉ូដសម្លៀកបំពាក់ធំជាងគេទីពីរនៅលើពិភពលោក បានបង្កឱ្យមានវិបត្តិនេះ នៅពេលដែលពួកគេបានលុបចោលការបញ្ជាទិញក្នុងអំឡុងខែមីនា ឆ្នាំ២០២០ និងកាត់បន្ថយការបញ្ជាទិញថ្មីៗយ៉ាងច្រើនសន្ធឹកសន្ធាប់ ដើម្បីឆ្លើយតបទៅនឹងភាពមិនប្រាកដប្រជានៃសេដ្ឋកិច្ចក្នុងអំឡុងខែដំបូងនៃការរាតត្បាតនៃជំងឺកូវីដ។

យោងតាមការសិក្សាស្រាវជ្រាវឆ្នាំ២០២០ របស់ AFWA ជាមួយកម្មករកាត់ដេរ កម្មករបាត់បង់ប្រាក់ឈ្នួលជាមធ្យម ៣ខែ ក្នុងអំឡុងឆ្នាំ២០២០ ។ កម្មករជាច្រើនមិនអាចបង់ថ្លៃផ្ទះជួល និងថ្លៃអាហារ ដោយមិនមានទាំងប្រាក់សន្សំ

និងជំពាក់បំណុលគេ ហើយគម្លាតប្រាក់បៀវត្សរ៍ទៅលើបញ្ហាយេនឌ័របានកើនឡើងនៅក្នុងឧស្សាហកម្មមួយ ដែលមានចំនួនកម្មករ ៨ នាក់ក្នុងចំណោមកម្មករ ១០ នាក់ជាស្ត្រី។

**ស្ថានភាពបច្ចុប្បន្ន ៖** សហជីពដែលតំណាងឱ្យកម្មករទាំងនេះនៅតាមបណ្តារោងចក្រ និងនៅកម្រិតវិស័យបានដាក់ពាក្យបណ្តឹងជាក់លាក់មួយ នៅក្រោមគោលការណ៍ណែនាំរបស់ **OECD** ស្តីពីការអនុវត្តសាជីវកម្មប្រកបដោយការទទួលខុសត្រូវ ទៅកាន់ **NCP** នៅក្នុងទីស្តីការរដ្ឋនៃសហរដ្ឋអាមេរិក ដោយធ្វើការចោទប្រកាន់ទៅក្រុមហ៊ុន **Nike** បានរួមចំណែកទៅលើលក្ខខណ្ឌរបស់កម្មករកាត់ដេរ នៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់របស់ខ្លួន តាមរយៈទំនាក់ទំនងជាមួយអ្នកផ្គត់ផ្គង់របស់ខ្លួន ប៉ុន្តែមិនបានដោះស្រាយ និងដោះស្រាយវាឡើងវិញ តាមគោលការណ៍ណែនាំនោះទេ។ សហជីពបង្ហាញថា កម្មករនៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់របស់ក្រុមហ៊ុន **Nike** បានប្រឈមមុខនឹង "ផលប៉ះពាល់សិទ្ធិមនុស្សធ្ងន់ធ្ងរ" បើយោងទៅតាមគោលការណ៍ណែនាំ ហើយក្រុមហ៊ុន **Nike** មិនបានឆ្លើយតបទៅនឹងសំណើរបស់សហជីព សម្រាប់ការពិភាក្សាអំពីផលប៉ះពាល់ទាំងនោះទេ ទោះបីជាគោលការណ៍ណែនាំរំពឹងថាក្រុមហ៊ុននឹងចូលរួមជាមួយនឹងសហជីព នៅពេលដែលពួកគេមានព័ត៌មានក្នុងចែករំលែកអំពីផលប៉ះពាល់ទៅលើបញ្ហាសិទ្ធិមនុស្សនៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់របស់ក្រុមហ៊ុនខ្លួន។

**ជំហានបន្ទាប់ ៖** ប្រសិនបើ NCP របស់សហរដ្ឋអាមេរិកយល់ព្រមលើបណ្តឹងដែលបានដាក់។ NCP នឹងអញ្ជើញ **Nike** ជាផ្លូវការដើម្បីឱ្យពិភាក្សាជាមួយសហជីព អំពីការទាមទាររបស់ពួកគេ និងជួយសម្រួលដល់ដំណើរការសន្ទនា ឬប្រសិនបើ **Nike** បដិសេធការសន្ទនា NCP អាចចេញអនុសាសន៍ដល់ក្រុមហ៊ុន **Nike** អំពីកម្មវត្ថុនៃកម្មករកាត់ដេរនៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់របស់ខ្លួន។

**សម្រាប់ព័ត៌មានបន្ថែមអំពីបណ្តឹង** OECD **ឬ យុទ្ធនាការ** Fight the Heist **សូមចូលទៅកាន់គេហទំព័រ ៖**

globallaborjustice.org និង asia.floorwage.org ឬក៏ទំនាក់ទំនងមកកាន់ កញ្ញា សាហ៊ីបា ហ្គីល (Sahiba Gill), មេធាវីបុគ្គលិកជាន់ខ្ពស់, sahibagill@globallaborjustice.org